ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ៣៣.៩១៦.សហវ.......

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃពុធ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២០

### ជម្រាបជូន
### លោកឧកញ៉ា ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**កម្មវត្ថុ:** ករណីសំណើសុំអនុញ្ញាតនាំចេញនូវមុខទំនិញម៉ាសគ្រប់ប្រភេទ។

**យោង:**- ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ លើលិខិតលេខ ៣៨១២ សហវ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- យោងសំណើរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកឧកញ៉ា** ជ្រាបថា យោងតាមសំណើរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ក្នុងបរិការណ៍នៃការរាតត្បាតជំងឺកូវីដ-១៩ ដែលកម្ពុជា និងសកលលោកកំពុងមានតម្រូវការម៉ាសគ្រប់ប្រភេទ សម្ភារពេទ្យ និងសម្លៀកបំពាក់សម្រាប់ការពារជំងឺឆ្លង (Personal Protective Equipment) រាជរដ្ឋាភិបាលកម្ពុជាគាំទ្រ និងលើកទឹកចិត្តឱ្យបណ្តារោងចក្រកាត់ដេរនៅកម្ពុជាចូលរួមធ្វើការផលិតម៉ាសគ្រប់ប្រភេទ សម្ភារពេទ្យ និងសម្លៀកបំពាក់សម្រាប់ការពារជំងឺឆ្លង (Personal Protective Equipment) សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបម្រើការនាំចេញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកឧកញ៉ា** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូម **លោកឧកញ៉ា** ទទួលនូវការរាប់អានពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- ក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666